សាលាទ្វេភាសា
បាមប៊ូចាយ៉ា

BAMBUJAYA
BILINGUAL SCHOOL

# កម្មវិធីសិក្សាថ្នាក់មត្តេយ្យនៅបាមប៊ូចាយ៉ា

## ការរៀនធ្វើការទំនាក់ទំនងនិងការអនុវត្តតាមរយៈការសហការគ្នា ការធ្វើត្រាប់តាម ការលេង និងទម្លាប់ប្រចាំថ្ងៃ

នៅថ្នាក់មត្តេយ្យ ក្មេងៗធ្វើការសង្កេតដោយយកចិត្តទុកដាក់ និងចូលចិត្តធ្វើត្រាប់តាម ដូច្នេះវាជាពេលវេលាដ៏ល្អបំផុតដើម្បីបង្រៀននូវទម្លាប់ល្អៗ និងការផ្តល់តម្លៃដែលទាំងនេះនឹងនៅស្ថិតស្ថេរក្នុងជីវិតរបស់គាត់។ ក្មេងៗចាប់អារម្មណ៍នូវអ្វីដែលមនុស្សពេញវ័យកំពុងធ្វើ និងចង់មាននូវអ្វីដែលខ្លួនឯងចង់ធ្វើ ហើយពេលវេលានឹងផ្តល់ឱកាសឲ្យពួកគេធ្វើការស្វែងយល់ពីពិភពលោកនិងអភិវឌ្ឍការស្រមើស្រមៃឲ្យកាន់តែប្រសើរ។ បន្ទាប់មក ពួកគេនឹងធ្វើការរួមបញ្ចូលការជឿងឆ្ងល់ជាមួយនឹងការយល់ពីសហគមន៍របស់ពួកគេក្នុងការផ្តល់ដំណោះស្រាយចំពោះបញ្ហាផ្សេងៗដែលកើតមានឡើង។

ដោយការយល់ដឹងយ៉ាងច្បាស់លាស់ពីការអប់រំតាមរយៈការធ្វើដោយដៃ ដោយចិត្ត និងដោយគំនិតប្រាជ្ញា បាមប៊ូចាយ៉ាផ្តល់ឱកាសនិងពេលវេលាគ្រប់គ្រាន់ដល់សិស្សានុសិស្សក្នុងការអភិវឌ្ឍជំនាញ អារម្មណ៍ និងចំណេះដឹងរបស់ពួកគេទៅតាមអាយុដែលសមស្រប។ នៅក្នុងកម្មវិធីសិក្សាថ្នាក់មត្តេយ្យរបស់យើង យើងផ្តល់ភាពកក់ក្តៅនិងសោភ័ណ្ឌភាពនៅក្នុងថ្នាក់រៀន សម្ភារលេង សិល្បៈ និងបរិស្ថានបែបធម្មជាតិដែលនាំអោយជីវិតគាត់មានភាពស្រស់បំព្រង។

ក្មេងៗរៀនពីភាសាផ្សេងៗ គណិតវិទ្យា ជំនាញសង្គមនិងការអនុវត្តតាមរយៈការលេង ការបំពេញការងារនិងការសហការ ហើយនៅក្នុងបរិយាកាសដែលប្រកបទៅដោយភាពរីករាយស្វាគមន៍រួមជាមួយនឹងទម្លាប់ប្រចាំថ្ងៃនិងសកម្មភាពប្រចាំសប្តាហ៍មួយចំនួនទៀតដូចជាការដុតនំ ការចម្អិនម្ហូបអាហារ ការផាត់ពណ៌ហត្ថកម្ម ការលេងល្បែងកម្សាន្តក្នុងនិងក្រៅថ្នាក់ និងការធ្វើការសម្អាតជាកត្តាជម្រុញអោយក្មេងៗមានការលូតលាស់យ៉ាងល្អប្រសើរទាំងផ្នែករាងកាយនិងប្រាជ្ញាស្មារតី។

ក្រោយពីបញ្ចប់កម្មវិធីសិក្សាថ្នាក់មត្តេយ្យនិងមុនឈានចូលកម្រិតថ្នាក់ទី១ សិស្សានុសិស្សនឹងអាចៈ

**ជំនាញភាសា**

- ស្តាប់ និងធ្វើតាមការណែនាំងាយៗ
- ស្តាប់អ្នកដទៃ និងអាចរង់ចាំវេនរបស់ខ្លួនដើម្បីនិយាយ
- រៀន និងអនុវត្តការប្រើប្រាស់ពាក្យតាមរយៈសកម្មភាពប្រចាំថ្ងៃ
- កត់សម្គាល់សម្លេងព្យញ្ជនៈតាមរយៈការស្តាប់និងការនិយាយ
- ធ្វើត្រាប់តាមការបញ្ចេញសម្លេងពាក្យជាភាសាខ្មែរនិងអង់គ្លេស
- និយាយល្បះពេញលេញ

- ស្ងូត្រកំណាព្យ និងច្រៀងចម្រៀង
- ប្រាប់ពីគំនិតនិងតម្រូវការ

### ជំនាញគណិតវិទ្យា

- រាប់លេខដើម្បីចូលរួមសកម្មភាពប្រចាំថ្ងៃ
- ចាប់ផ្តើមយល់ពីចំនួននិងសារៈសំខាន់របស់វា
- ធ្វើការបែងចែករបស់ផ្សេងៗគ្នាទៅតាមក្រុម
- កត់សម្គាល់ការសរសេរលេខ
- ដឹងពីលំនាំនិងជំហានក្នុងការអនុវត្តកិច្ចការងាយៗ

### ជំនាញផ្នែកសង្គម និងអារម្មណ៍

- បង្ហាញការគោរព ការយល់ចិត្ត និងការយកចិត្តទុកដាក់លើអ្នកដទៃ
- បង្ហាញពីភាពឯករាជ្យនៅក្នុងទម្លាប់ប្រចាំថ្ងៃ
- ធ្វើការសហការជាមួយអ្នកដទៃដើម្បីសម្រេចកិច្ចការ
- បង្ហាញការស្រឡាញ់និងថែទាំថ្នាក់រៀនអោយល្អប្រសើរ
- មានអាកប្បកិរិយាល្អ
- អនុវត្តការគ្រប់គ្រងខ្លួនឯង
- មានទំនុកចិត្តលើខ្លួនឯងនិងសមត្ថភាពក្នុងការបំពេញកិច្ចការងាយៗ

### បំណិនជីវិតនិងការប្រើប្រាស់កាយសម្បទា

- អនុវត្តការធ្វើអនាម័យល្អ
- ជួយរៀបចំអាហារសម្រន់
- ជួយធ្វើការសម្អាតប្រចាំថ្ងៃ
- អភិវឌ្ឍការសហការរវាងដៃនិងភ្នែកតាមរយៈការដេរប៉ាក់និងការកែច្នៃដែលមានលំនាំច្បាស់លាស់
- អភិវឌ្ឍការធ្វើការរួមគ្នានិងការរក្សាលំនឹងលើរាងកាយតាមរយៈការលេងនៅខាងក្រៅ ការឡើងចុះ ការរត់ និងការជីករុករក
- អនុវត្តសកម្មភាពប្រចាំថ្ងៃដូចជាការរៀបចំទុកដាក់ និងការសម្អាត

## Early Childhood Bilingual Program at Bambujaya

***Learning social and practical skills through cooperation, imitation, play and daily routine***

During the early years, children carefully watch and imitate, so it is the perfect time to teach good habits and values that will last a lifetime. They are interested in what adults are doing and want to have purposeful work themselves, but they also need plenty of time to safely explore the world and develop a rich imagination. Later, they can combine their curiosity and compassion to understand the world better and offer solutions to problems.

By beginning with a strong understanding of how to educate the hands, heart and head, we at Bambujaya give our learners enough time to develop skills, feelings and knowledge in age appropriate ways. In our Early Childhood Program, we encourage wonder and joy for the goodness of life through the warmth and beauty of the classrooms, toys, art and natural setting.

Through play, purposeful tasks and cooperation, children learn a variety of language, math, social and practical skills. Our welcoming and caring environment, along with daily and weekly routines includes baking, cooking, painting, handwork crafts, games, outdoor play and housekeeping chores. All of this promotes the healthy growth of the child's body and mind.

At the completion of our Early Childhood Program, and before entering Grade 1, learners should be able to:

## Language skills

- Listen to and follow simple 2 step instructions
- Listen to others and wait for their turn to speak
- Learn and practise vocabulary through daily activity
- Identify familiar letter sounds through listening and speaking
- Imitate proper pronunciation of common English and Khmer words
- Form appropriate sentence structure
- Recite poems and sing songs
- Communicate basic needs and ideas

## Math skills

- Count to carry out practical activities
- Understand the concept of numbers and their importance in daily life
- Sort various objects
- Recognise written numbers
- Sequence and plan steps for simple tasks

## Social/Emotional skills

- Show respect, empathy and care for others
- Show independence in daily habits
- Cooperate with others to achieve tasks
- Show gratitude for, and take care of, the classroom environment
- Understand and use good manners
- Practise self-control
- Show self-confidence and competence in simple tasks

## Practical Life/Physical skills

- Practise good hygiene
- Help with snack preparation
- Assist with daily chores
- Develop fine motor skills through handwork and detailed crafts (hand eye coordination)
- Develop gross motor skills through various outdoor play, e.g. climbing, running, digging and swinging (coordination and balance)
- Follow the routine of the day, including setup and cleanup